# Monthly Report Volume 41

**May 2025**

## Project Activities in May:

- 7th–8th : TOT3 in BTB (Communication / Nursing Informatics)
- 8th : Meeting with HRDD, BTB PHD, RTC & PRH
- 12th : Monthly Meeting with JICA HQ / Cambodia Office
- 21st–22nd : TOT3 in KC (Basic Nursing Skill / Nursing Management & Leadership)
- 21st : Meeting with HRDD, HSD, KC PHD, RTC & PRH
- 28th–29th : TOT3 in KC (Nursing Process Application / QI & Patient Safety)

## Coordination Meetings for INSET Implementation in KC and BTB

On 21st May 2025, the Project team, along with Assist. Prof. Dr. TOUCH Sokneang, Director of the Human Resource Development Department (HRDD) and Project Manager, and Assist. Prof. Dr. KOY Virya, Deputy Director of Hospital Service Department (HSD) and Chair of the Training Management Team (TMT), held a coordination meeting with Directors, Deputy Directors, and key members of the Kampong Cham (KC) Provincial Health Department (PHD), Regional Training Center (RTC), and Provincial Referral Hospital (PRH) to discuss the implementation plan for In-service Training (INSET) in KC following the completion of Training of Trainers (TOT3).

During the meeting, the formation of a Provincial Training Management Team (P-TMT) was proposed to ensure smooth implementation of the upcoming INSET sessions. Assist. Prof. Dr. TOUCH Sokneang emphasized the importance of strong commitment from the KC team and encouraged coordination with the national project members. KC side agreed to take responsibility for key tasks, such as nominating P-TMT members and preparing the INSET implementation plan.

Prior to KC, a similar meeting was held in Battambang (BTB), on 8th May where the second round of INSET planning discussions took place. The Project will continue to collaborate closely with both provinces to ensure successful and high-quality INSET training for nurses.



Meeting at BTB PHD







Meeting at KC PHD

## TOT3 Lectures Completed : Trainers Prepare for Final Demonstrations

Since December 2024, the Project has been conducting Training of Trainers (TOT) for future INSET trainers in BTB and KC. In May 2025, the final round of lecture-based courses was completed, covering six key topics. For the Communication and Nursing Informatics courses in BTB, and Nursing Process Application and Quality Improvement & Patient Safety courses in KC, Assist. Prof. Dr. TOUCH Sokneang, Director of HRDD and the Project Manager, joined the sessions for supervision. She encouraged participants to take initiative as new trainers and emphasized the importance of transferring knowledge effectively to frontline practice. In June, each trainer candidate will conduct a demonstration lesson in front of senior trainers. These sessions will allow them to practice delivering what they've learned and receive individual feedback. The demonstrations mark the final step of the TOT process.

Following this, the newly trained provincial trainers will begin implementing INSET sessions according to the provincial training plans. The ultimate goal of INSET is to translate classroom-based knowledge into improved practices in clinical settings. To ensure the quality of implementation, the Project will also focus on monitoring and evaluation of both trainer performance and training content. The Project remains committed to working closely with HRDD, the provincial teams, and the National and Provincial Training Management Teams (N-TMT, P-TMT) to achieve this goal.



Opening Session for NM&L/BNS courses in KC





TOT3 in KC



## UPCOMING ACTIVITIES IN JUNE

- 3rd : Monthly Meeting with JICA HQ / Cambodia Office
- 10th–13th: TOT3 Demonstration in BTB
- 24th–27th : TOT3 Demonstration in KC

## CONTACT INFORMATION


**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage

Monthly Report
Volume 41

ឧសភា
២០២៥

## សកម្មភាពគម្រោងប្រចាំខែឧសភា៖

- ថ្ងៃទី៧ និងទី៨ ៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តបាត់ដំបង)
  - វគ្គការប្រាស្រ័យទាក់ទង និងវគ្គព័ត៌មានវិទ្យា នៃការថែទាំ
- ថ្ងៃទី៨៖ កិច្ចប្រជុំជាមួយ HRDD, BTB PHD, RTC & PRH
- ថ្ងៃទី១២៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និង ការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី២១ ដល់ទី២២៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តកំពង់ចាម)
  - វគ្គជំនាញមូលដ្ឋាន នៃការថែទាំ និងវគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ
- ថ្ងៃទី២១៖ កិច្ចប្រជុំជាមួយ HRDD,HSD, KC PHD, RTC & PRH
- ទី២៨ ដល់ទី២៩៖ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ខេត្តកំពង់ចាម)
  - វគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំជំងឺ និងវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ

## កិច្ចប្រជុំសម្របសម្រួលសម្រាប់ការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នៅ ខេត្តកំពង់ចាម និង ខេត្តបាត់ដំបង

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារគម្រោង រួមជាមួយនឹងលោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) និងជាប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង និងលោកបណ្ឌិត កុយ វីរីយ៉ា អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ (HSD) និងជាប្រធានក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (TMT) បានជួបប្រជុំជាមួយ ឯកឧត្តមប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម (PHD) លោកនាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ (RTC) លោកប្រធានមន្ទីរពេទ្យខេត្ត (PRH) និងមន្ត្រីក្រោមឱវាទផ្សេងទៀត ដើម្បីពិភាក្សាអំពីផែនការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នៅក្នុងខេត្តកំពង់ចាម ដែលបន្តពីវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT3)។

ការបង្កើតក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត (P-TMT) ត្រូវបានស្នើឡើងក្នុងកិច្ចប្រជុំនេះ ដើម្បីធានាឱ្យការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នាពេលខាងមុខប្រកបដោយប្រសិទ្ធភាព។ លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់មន្ត្រីគ្រប់ជាន់ថ្នាក់នៃមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកំពង់ចាម និងលើកទឹកចិត្តឱ្យមានការសម្របសម្រួលជាមួយបុគ្គលិកគម្រោង និងមន្ត្រីថ្នាក់ជាតិបន្តទៀត។ ឯកឧត្តមប្រធានមន្ទីរសុខាភិបាល បានឯកភាពលើការងារសំខាន់ៗ ដូចជាការតែងតាំងក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត និងរៀបចំផែនការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក ។

មុនពេលកិច្ចប្រជុំជាមួយមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកំពង់ចាម គម្រោងក៏បានរៀបចំកិច្ចប្រជុំស្រដៀងគ្នានេះ ជាមួយមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបាត់ដំបង នៅថ្ងៃទី៨ ខែឧសភា ដែលជាកិច្ចប្រជុំលើកទីពីរ ដើម្បីពិភាក្សាបន្តអំពីការធ្វើផែនការ INSET។ គម្រោងនឹងបន្តសហការយ៉ាងជិតស្និទ្ធជាមួយខេត្តទាំងពីរ ដើម្បីធានាបាននូវការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ប្រកបដោយជោគជ័យ និងមានគុណភាពខ្ពស់។

Meeting at BTB PHD









Meeting at KC PHD

## ការបង្រៀន វគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT3) បានបញ្ចប់៖ គ្រូបង្គោលរៀបចំសម្រាប់ការអនុវត្តការបង្រៀនសាកល្បង

ចាប់តាំងពីខែធ្នូ ឆ្នាំ២០២៤ មក គម្រោងបាន និងកំពុងដំណើរការវគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) សម្រាប់អនាគតគ្រូបង្គោលថ្មី ក្នុងការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នៅក្នុងខេត្តបាត់ដំបង និងខេត្តកំពង់ចាម។ នៅខែឧសភា ឆ្នាំ២០២៥ ដែលជាជុំចុងក្រោយនៃវគ្គបណ្តុះបណ្តាលផ្អែកលើការបង្រៀនជាក់ស្តែង បានបញ្ចប់ដែលគ្របដណ្តប់លើប្រធានបទសំខាន់ៗចំនួនប្រាំមួយ។ លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) និងជាប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង បានចូលរួម និងត្រួតពិនិត្យការបណ្តុះបណ្តាលវគ្គការប្រាស្រ័យទាក់ទង និងវគ្គព័ត៌មានវិទ្យា នៃការថែទាំ នៅខេត្តបាត់ដំបង និងវគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំជំងឺ និងវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺនៅខេត្តកំពង់ចាម។ លោកស្រីសាស្ត្រាចារ្យជំនួយ បានលើកទឹកចិត្តអ្នកចូលរួមដែលជាគ្រូបង្គោលថ្មី និងសង្កត់ធ្ងន់លើសារៈសំខាន់នៃការផ្ទេរចំណេះដឹងប្រកបដោយប្រសិទ្ធភាពដល់ការអនុវត្តជួរមុខ។ នៅខែមិថុនា សិក្ខាកាមដែលជាគ្រូបង្គោលថ្មីនីមួយៗ នឹងអនុវត្តការបង្រៀនសាកល្បងនៅមុខគ្រូបង្គោលដែលបានបណ្តុះបណ្តាលមុន។ ការបង្រៀនសាកល្បងនេះនឹងអនុញ្ញាតឱ្យពួកគេអនុវត្ត និងចែករំលែកនូវអ្វីដែលពួកគេបានរៀន នឹងទទួលបានពីមតិកែលម្អសម្រាប់បុគ្គលម្នាក់ៗ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល។ ការអនុវត្តការបង្រៀនសាកល្បងនេះគឺជាជំហានចុងក្រោយនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល(TOT)។

បន្ទាប់ពីនេះ គ្រូបង្គោលថ្មីដែលទទួលបានវគ្គបណ្តុះបណ្តាលរួចនឹងចាប់ផ្តើមអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក តាមផែនការបណ្តុះបណ្តាលថ្នាក់ខេត្ត។ គោលដៅចុងក្រោយរបស់ INSET គឺដើម្បីក្រែប្រែចំណេះដឹងដែលមានមូលដ្ឋានពីថ្នាក់រៀនទៅជាការអនុវត្តដែលប្រសើរឡើងនៅក្នុងកន្លែងព្យាបាលផ្ទាល់។ ដើម្បីធានាបាននូវគុណភាពនៃការអនុវត្ត គម្រោងក៏នឹងផ្តោតលើការត្រួតពិនិត្យ និងវាយតម្លៃទាំងការអនុវត្តរបស់គ្រូបណ្តុះបណ្តាល និងខ្លឹមសារបណ្តុះបណ្តាល។ គម្រោងនៅតែប្តេជ្ញាធ្វើការយ៉ាងជិតស្និទ្ធជាមួយ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស មន្ត្រីថ្នាក់ខេត្ត និងក្រុមគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ជាតិ (N-TMT) រួមនឹងក្រុមគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត (P-TMT) ដើម្បីសម្រេចបាននូវគោលដៅនេះ។



Opening Session
for NM&L/BNS courses
in KC



TOT3 in KC



## សកម្មភាពនាពេលខាងមុខក្នុងខែមិថុនា

- ថ្ងៃទី៣៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និង ការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី១០ ដល់ថ្ងៃទី១៣៖ ការបង្រៀនសាកល្បងសម្រាប់គ្រូបង្គោល TOT3 នៅ BTB
- ថ្ងៃទី២៤ ដល់ថ្ងៃទី២៧៖ ការបង្រៀនសាកល្បងសម្រាប់គ្រូបង្គោល TOT3 នៅ KC

**CONTACT INFORMATION**

Scan here to find out more about us:

JICA's FB Page

Project's Homepage

**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh